ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សន្ទរកថា

## របស់ឯកឧត្តម លឹម សុគុន រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ថ្លែងក្នុងពិធីធ្វើមិទិញអបអរសាទរទិវាតំបន់ដីសើមពិភពលោក

## ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៦ នៅសួនច្បារវិទ្យាល័យចតុមុខ ក្រុងភ្នំពេញ

[illegible]

**សូមគោរព :**

- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាគណៈអធិបតីជាទីគោរព
- ឯកឧត្តមភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ព្រមទាំងអ្នកតំណាងអង្គការជាតិ-អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ជាទីរាប់អាន
- ព្រមទាំងប្អូនៗនិស្សិតជាទីស្រឡាញ់

តាងនាមមន្ត្រីរាជការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយសយ៉ាងខ្ពង់ខ្ពស់ប្រកបដោយសេចក្តីសោមនស្សរីករាយបំផុត ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ អស់លោក លោកស្រីតំណាងអង្គការជាតិ-អន្តរជាតិ ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ និងប្អូនៗជានិស្សិត ក្នុងឱកាសប្រារព្ធមិទិញអបអរសាទរទិវាតំបន់ដីសើមពិភពលោក ដែលរៀបចំឡើងដោយក្រសួងបរិស្ថាន និងកម្មវិធីអភិរក្ស និង ប្រើប្រាស់ដោយនិរន្តរភាពនូវជីវចំរុះតំបន់ដីសើមទន្លេ មេគង្គ ដែលមានសារៈសំខាន់នាថ្ងៃនេះ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ប្អូនៗនិស្សិតជាពិសេសចំពោះអង្គការខុនសឺន, អង្គការស៊ីដសេ, អង្គការអប់រំពិភព លោក អង្គការអុកស្វាម, អង្គការសេដាក, សមាគមអភិរក្សបរិស្ថាន និងវប្បធម៌, អង្គការព្រៃឈើ និងសត្វព្រៃអន្តរជាតិ មូលនិធិសត្វក្រៀលអន្តរជាតិ, អង្គការសង្គ្រោះសត្វព្រៃកម្ពុជា, WCS, អង្គការអភិរក្សអន្តរជាតិ, អង្គការស្បៀងអាហារនិងកសិកម្ម, អង្គការមូប់បៃតង, អង្គការសត្វស្លាបអន្តរជាតិ, មជ្ឈមណ្ឌលត្រីពិភពលោក ដែលបានធ្វើ និងកំពង់សហប្រតិបត្តិការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន។

**គណៈអធិបតី** ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងប្អូនៗនិស្សិតជាទីគោរព រាប់អាន

ព្រះរាជាណាចក្រកម្ពុជាយើង ជាប្រទេសមួយមានភ័ព្វសំណាងជាងគេក្នុងចំណោមបណ្តាប្រទេសស្ថិតនៅក្នុងអាងទន្លេមេគង្គ ដែលសំបូរដោយធនធានធម្មជាតិ ពិសេសព្រៃឈើ សត្វព្រៃ ត្រី ។ល។ តាមការស្រាវជ្រាវរបស់អ្នកឯក

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B.V.D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352 Fax : (855) 23 - 217 320

ទេសតំបន់ដីសើមបានអោយដឹងថា ប្រទេសកម្ពុជាយើងគ្របដណ្តប់ដោយតំបន់ដីសើមប្រមាណ ៣០% នៃផ្ទៃប្រទេស គឺប្រមាណ ៥៤,៣ពាន់គីឡូម៉ែត្រការេ ហើយប្រមាណ ២០% ដែលមានសារៈសំខាន់សំរាប់អន្តរជាតិ ហើយចែកចេញជាបួនកន្លែង : (១). ទន្លេមេគង្គ (២). ទន្លេសាប (៣).ស្ទឹងសែន (៤).តំបន់ពាមសមុទ្រនៃស្ទឹងកោះប៉ោ និងស្ទឹងកែប ។

តាំងពីយូរយាណាស់មកហើយយើងគ្រប់គ្នាពុំបានអើពើចំពោះតំបន់ដីសើមឡើយដោយយើងពុំបានយល់ច្បាស់ពីសារៈប្រយោជន៏ និងតំលៃសេដ្ឋកិច្ចពិតៗរបស់វា ។

តំបន់ដីសើម ជាប្រព័ន្ធជីវចំរុះ មានទំនាក់ទំនងតាមធម្មជាតិយ៉ាងល្អប្រសើរ។ ប្រជាជនកម្ពុជាភាគច្រើនរស់នៅ និងប្រកបរបរអាជីវកម្មចិញ្ចឹមជីវិតលើតំបន់ដីសើមអស់រយៈពេលជាច្រើនសតវត្សមកហើយ ដូចជាការប្រកបរបរកសិកម្ម និង នេសាទ ពិសេសគឺនៅភាគកណ្តាលនៃផ្ទៃប្រទេស គឺតំបន់ដែលស្ថិតនៅជុំវិញបឹងទន្លេសាប ។

តំបន់ដីសើមនៅកម្ពុជា ក៏សំបូរដោយព្រៃលិចទឹក ផ្តល់កន្លែងសំរាប់ជំរកត្រីរស់នៅ ពង ហេតុនេះវាមានតួនាទីស្នូលក្នុងការទ្រទ្រង់ប្រូតេអ៊ីននៅកម្ពុជា។ តំបន់ដីសើមទ្រទ្រង់ផលិតកម្មស្រូវ និងត្រី ដែលជាប្រភពចំបងនៃអាហារសំរាប់ប្រជាពលរដ្ឋខ្មែរច្រើនលើសលុប។ បន្ថែមលើការទ្រទ្រង់កសិកម្ម និងជលផល តំបន់ដីសើមមានតួនាទីស្នូលក្នុងការទ្រទ្រង់វដ្តទឹក និងការពារតំបន់នានាពីការលិចលង់នៃទឹកជំនន់ បើនៅឆ្នេរសមុទ្រវិញ វាការពារទប់ទល់នឹងខ្យល់ព្យុះ និងការពារខ្សែឆ្នេរពីការហូរច្រោះ។ តំបន់ដីសើមនៅកម្ពុជាមានសារៈសំខាន់យ៉ាងច្រើនស្ទើរតែរាប់មិនអស់ មកដល់ពេលនេះ យើងទាំងអស់គ្នាត្រូវតែដឹងពីសារៈប្រយោជន៏របស់វា ទើបយើងងាយការពារ និងអភិវឌ្ឍន៏បានល្អ ដោយមានពាក្យមួយសំរាប់អ្នកបច្ចេកទេសព្រៃឈើ និងសត្វព្រៃបានចែងថា "ស្គាល់ ស្រលាញ់ ការពារ" ។

តំបន់ដីសើម :

- ជាប្រព័ន្ធច្រោះសំអាតទឹកក្រខ្វក់ និងច្រោះយកល្បាប់ភក់ ជំរុញអោយរុក្ខជាតិដុះលូតលាស់ល្អ និងកែលំអរគុណភាពទឹក
- ជាអាងតំកល់ទឹកទុកសំរាប់ប្រើប្រាស់នៅរដូវប្រាំង ក៏ដូចជាកាត់បន្ថយនូវគ្រោះទឹកជំនន់ នៅរដូវវស្សា
- មានធនធានសំរាប់ប្រើប្រាស់រួមមាន វារីវប្បកម្ម ទេសចរណ៍ ការដឹកជញ្ជូនផ្លូវទឹក និងថាមពល (វារីអគ្គិសនី)

លើសពីនេះ តំបន់ដីសើមនៅកម្ពុជា មានសារៈសំខាន់បន្ថែមទៀត គឺជាដែនជំរក បំរុងសត្វស្លាប និង សត្វព្រៃផ្សេងៗ ដែលគេពុំសូវជួបប្រទះឃើញមាននៅក្នុងប្រទេសផ្សេងទៀត ដូចជា សត្វក្រៀល ខ្សឹប ត្រយ៉ងយក្ស ត្មាតផេះទាព្រៃស្លាបស និងពពួកសត្វស្លាប មួយចំនួនទៀត ដែលជាពពួកសត្វស្លាបមានដោយកំរ និងជិតផុតពូជ។ នៅតំបន់ដីសើមដែលជាជំរកសត្វស្លាប ក្រសួងកសិកម្ម បាននឹងកំពង់សហការជាមួយអង្គការអន្តរជាតិមួយចំនួន មានជាអាទិ៍អង្គការសត្វស្លាបអន្តរជាតិ មូលនិធិសត្វក្រៀលអន្តរជាតិ ជាដើមដើម្បីធ្វើការត្រួតពិនិត្យស្រាវជ្រាវ អភិរក្សនៅតំបន់មួយចំនួនក្នុងនោះមាន : តំបន់បឹងព្រែកល្ពៅ ស្ថិតនៅស្រុកបុរីជលសា ស្រុកកោះអណ្តែតខេត្តតាកែវ តំបន់គ្រប់គ្រង និងអភិរក្សដែនជំរកសត្វក្រៀលអាងត្រពាំងថ្ម ក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យត្រូវបានកំណត់ដោយ ព្រះរាជក្រឹត្យនៅខែកុម្ភៈឆ្នាំ២០០០ ។ នៅពេលថ្មីៗនេះទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានរកឃើញ ដែនជំរកសត្វក្រៀល

មួយកន្លែងទៀត នៅស្រុកកំពង់ត្រាច ខេត្តកំពត ហើយក្រសួងក៏កំពង់រៀបចំធ្វើប្រកាស ដើម្បីការពារនូវពពួកសត្វដ៏កំរជិតផុតពូជទាំងអស់នោះ។ និយាយរួម តំបន់ដីសើមនៅកម្ពុជាមានចំណងទាក់ទងជិតស្និទទាំងខាងផ្នែកវប្បធម៌ និងសេដ្ឋកិច្ច ហើយក៏មានសារៈសំខាន់ផងដែរសំរាប់ការស្រាវជ្រាវ និងការអប់រំ ។

ប៉ុន្តែនាពេលថ្មីៗនេះ តំបន់ដីសើមកម្ពុជា ត្រូវបានទទួលរងនូវការគំរាមកំហែងដោយសកម្មភាពផ្សេងៗរបស់មនុស្សដូចជា :

- ការកាប់ទន្រ្ទានបំផ្លាញដីព្រៃឈើ និងព្រៃលិចទឹក ដើម្បីធ្វើជាកម្មសិទ្ធិ អុស ធ្យូង
- ការចាក់បំពេញ និងការលើកទំនប់សំរាប់បំរើវិស័យផ្សេងៗ
- ការប្រើជីគីមី និងថ្នាំសំលាប់សត្វល្អិត
- ការបញ្ចេញចោលកាកសំណល់រឹង-រាវ និងការធ្វើអាជីវកម្មរ៉ែផ្សេងៗ ជាដើម

ដែលកន្លងមកយើងពុំទាន់បានសិក្សាស៊ីជំរៅ ជាលក្ខណៈវិទ្យាសស្រ្ត នូវផលប៉ះពាល់របស់វានៅឡើយ ។

តែទោះជាយ៉ាងនេះក្តី នាបច្ចុប្បន្ននេះ រាជរដ្ឋាភិបាល ដែលមានសម្តេច **ហ៊ុន សែន** ជាប្រមុខ ក៏ដូចជាបណ្តាប្រទេសផ្សេងៗទៀតក្នុងពិភពលោក បាននឹងកំពង់តែយកចិត្តទុកដាក់រិះរកគ្រប់មធ្យោបាយក្នុងការពារថែរក្សា និងគ្រប់គ្រងតំបន់ដីសើម និងអភិវឌ្ឍន៍ដោយនិរន្តរភាព។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមចូលរួមគាំទ្រការរៀបចំផែនការ និងការអនុវត្តន៍សកម្មភាពនានាដែលធ្វើអោយរីកចំរើនខាងស្មារតី ចេះស្រលាញ់ ការពារ ថែរក្សាតំបន់ដីសើម អោយស្ថិតស្ថេរគង់វង់យូរអង្វែង និងមានសារៈប្រយោជន៍ដល់មនុស្សជាតិគ្រប់រូប ។

**គណៈអធិបតី** ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងប្អូនៗនិស្សិតជាទីគោរពរាប់អាន

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា តាមរយៈវត្តមានចូលរួមយ៉ាងសកម្មជាមួយទេពកោសល្យ បទពិសោធន៍ និងការគាំទ្រដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ-អន្តរជាតិ អង្គមិទ្ទិញនាពេលនេះ នឹងក្លាយទៅជាកាលានុវត្តន៍ និងជាឧត្តមប្រយោជន៍ដ៏ថ្លៃថ្លា សំរាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ដីសើមប្រកបដោយនិរន្តរភាព។

ជាមួយនឹងក្តីសង្ឃឹមដ៏មុតមាំនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារ ដែលជាអង្គការ និងសមាគមជាតិ-អន្តរជាតិ ដែលបាននឹងកំពង់ជួយការពារ និងអភិវឌ្ឍន៍តំបន់ដីសើមនៅកម្ពុជានាពេលនេះ។

ទីបញ្ចប់សូមអោយ **ទិវាតំបន់ដីសើមពិភពលោក** បានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ទទួលបានលទ្ធផលល្អ និង សូមប្រសិទ្ធិពរជ័យជូនគណអធិបតី ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ព្រមទាំងប្អូនៗនិស្សិត ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ទទួលបាននូវជ័យជំនះ និងសុភមង្គលគ្រប់ប្រការ។

*សូមអរគុណ!*